អ អ ក

EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ០៥៤៤/១៧ អអក

ភ្នំពេញ, ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧

# សេចក្តីណែនាំ និងវិធានការចំពោះការទូទាត់ថ្លៃអគ្គិសនី

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនអ្នកកាន់អាជ្ញាបណ្ណធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជាទាំងអស់ឲ្យបានជ្រាបថា ពេលថ្មីៗនេះមានអ្នកកាន់អាជ្ញាបណ្ណមួយចំនួនមានការយឺតយ៉ាវក្នុងការទូទាត់ថ្លៃទិញប្រភពអគ្គិសនីឲ្យអគ្គិសនីកម្ពុជា ឬឲ្យអ្នកធ្វើសេវាកម្មបញ្ជូនរងឯកជន ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមជម្រាបជូនថា និរន្តរភាពនៃប្រតិបត្តិការអាជីវកម្មអគ្គិសនីដែលបិតនៅក្នុងប្រភពអគ្គិសនីពីបណ្តាញជាតិ គឺបានមកពីការទូទាត់ថ្លៃអគ្គិសនីឲ្យបានទាន់ពេលវេលាជាបន្តបន្ទាប់ពីអ្នកប្រើប្រាស់ឲ្យទៅអ្នកចែកចាយ ពីអ្នកចែកចាយឲ្យទៅអ្នកបញ្ជូនរង ពីអ្នកបញ្ជូនរងឲ្យទៅបណ្តាញជាតិ និងពីបណ្តាញជាតិឲ្យទៅអ្នកផលិត ។ ដូច្នេះ ប្រសិនបើមានការទូទាត់យឺតយ៉ាវនៅផ្នែកណាមួយក្នុងរចនាសម្ព័ន្ធទូទាត់ដែលជម្រាបជូននេះ វានឹងបណ្តាលឲ្យប៉ះពាល់ដល់និរន្តរភាពនៃអាជីវកម្មផ្គត់ផ្គង់អគ្គិសនីមួយផ្នែក ឬ អាជីវកម្មផ្គត់ផ្គង់អគ្គិសនីនៅកម្ពុជាទាំងមូល ។ ចំពោះលក្ខខណ្ឌនៃការទូទាត់ថ្លៃអគ្គិសនីរបស់អ្នកប្រើប្រាស់ឲ្យទៅអ្នកចែកចាយ មានកំណត់នៅក្នុង "បទប្បញ្ញត្តិស្តីពីលក្ខខណ្ឌទូទៅក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា" រួចហើយ ដោយឡែក លក្ខខណ្ឌនៃការទូទាត់ថ្លៃអគ្គិសនីរបស់អ្នកចែកចាយឲ្យអ្នកបញ្ជូនរងដែលអាចជាអគ្គិសនីកម្ពុជា ឬជាអ្នកធ្វើសេវាកម្មបញ្ជូនរងឯកជន មានកំណត់នៅក្នុង "កិច្ចព្រមព្រៀងលក់-ទិញអគ្គិសនី" រវាងភាគីទាំងពីររួចហើយ ។ បច្ចុប្បន្ននេះ អាជ្ញាធរអគ្គិសនីកម្ពុជាសង្កេតឃើញថា អ្នកប្រើប្រាស់អគ្គិសនីទូទៅបានបង់ថ្លៃអគ្គិសនីឲ្យទៅអ្នកចែកចាយតាមការកំណត់រួចហើយ ប៉ុន្តែមានអ្នកចែកចាយខ្លះមិនបានបង់បន្ត ឬមិនបានបង់ឲ្យទាន់ពេលវេលាឲ្យអ្នកបញ្ជូនរងទាំងអគ្គិសនីកម្ពុជា ឬទាំងអ្នកធ្វើសេវាកម្មបញ្ជូនរងឯកជនឡើយ ដែលអាចធ្វើឲ្យគ្រោះថ្នាក់ដល់និរន្តរភាពនៃអាជីវកម្មអគ្គិសនីបន្តគ្នាជារួមនៅកម្ពុជា ។ ដូច្នេះ ដើម្បីចៀសវាងគ្រោះថ្នាក់ដល់និរន្តរភាពនៃអាជីវកម្មអគ្គិសនីបន្តគ្នាជារួមនៅកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសូមធ្វើការណែនាំយ៉ាងម៉ឺងម៉ាត់ចំពោះអ្នកកាន់អាជ្ញាបណ្ណទាំងអស់ឲ្យធ្វើការទូទាត់ថ្លៃទិញប្រភពអគ្គិសនីឲ្យទាន់ពេលវេលាតាមការកំណត់ក្នុងកិច្ចព្រមព្រៀងលក់-ទិញអគ្គិសនីរវាងភាគីទាំងពីរ (ទាំងការទូទាត់ឲ្យអគ្គិសនីកម្ពុជា និងឲ្យអ្នកធ្វើសេវាកម្មបញ្ជូនរងឯកជន) ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមជម្រាបជូនអ្នកកាន់អាជ្ញាបណ្ណទាំងអស់ថា ប្រសិនបើអ្នកកាន់អាជ្ញាបណ្ណណាដែលធ្វើការទូទាត់យឺតយ៉ាវធ្វើឲ្យប៉ះពាល់ដល់និរន្តរភាពនៃអាជីវកម្មអគ្គិសនីដូចខាងលើ អាជ្ញាធរអគ្គិសនីកម្ពុជានឹងចាត់វិធានការដូចខាងក្រោម ៖

- បើមានលើកទី១ អាជ្ញាធរអគ្គិសនីកម្ពុជានឹងចេញការព្រមានលើកទី១ និងស្នើសុំទៅមូលនិធិអគ្គិសនីការូបនីយកម្មជនបទ ឲ្យផ្អាកការផ្តល់ថវិកាឧបត្ថម្ភធន រហូតដល់មានការទូទាត់

អាជ្ញាធរអគ្គិសនីកម្ពុជា : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៥៤ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

ត្រឹមត្រូវឡើងវិញ ទើបមូលនិធិអគ្គិសនីការូបនីយកម្មជនបទផ្តល់ឲ្យជាធម្មតាវិញ ។

- បើមានលើកទី២ អាជ្ញាធរអគ្គិសនីកម្ពុជានឹងចេញការព្រមានលើកទី២ និងស្នើសុំទៅមូលនិធិអគ្គិសនីការូបនីយកម្មជនបទ ឲ្យផ្អាកការផ្តល់ថវិកាឧបត្ថម្ភធន ព្រមទាំងធ្វើការផាកពិន័យតាមមាត្រា៦៤ នៃច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។ ការផ្អាកផ្តល់ថវិកាឧបត្ថម្ភធនត្រូវអនុវត្តរហូតដល់អ្នកកាន់អាជ្ញាបណ្ណបានធ្វើការទូទាត់ត្រឹមត្រូវឡើងវិញ បានបង់ប្រាក់ពិន័យរួចរាល់ និងបានធ្វើកិច្ចសន្យាឈប់ប្រព្រឹត្តិខុសតទៅទៀត ។
- បើមានលើកទី៣ អាជ្ញាធរអគ្គិសនីកម្ពុជានឹងចេញការព្រមានលើកទី៣ និងស្នើសុំទៅមូលនិធិអគ្គិសនីការូបនីយកម្មជនបទ ឲ្យផ្អាកការផ្តល់ថវិកាឧបត្ថម្ភធន និងធ្វើការដកហូតអាជ្ញាបណ្ណលែងឲ្យធ្វើសេវាកម្ម ។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ អាជ្ញាធរអគ្គិសនីកម្ពុជាសូមអំពាវនាវដល់គ្រប់អ្នកកាន់អាជ្ញាបណ្ណអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ចូលរួមអនុវត្តតាមការណែនាំខាងលើនេះឲ្យមានប្រសិទ្ធភាពដើម្បីរក្សាបាននូវនិរន្តរភាពនៃការធ្វើអាជីវកម្មអគ្គិសនីទាំងមូលក្នុងប្រព័ន្ធបណ្តាញជាតិ ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

**ចម្លងជូន**
-ក្រសួងរ៉ែ និងថាមពល
-សាលារាជធានី-ខេត្ត
-អគ្គិសនីកម្ពុជា
-មន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត
-សាលាក្រុង-ខណ្ឌ-ស្រុក
"ដើម្បីជូនជ្រាបជាព័ត៌មាន"
-ឯកសារ និងកាលប្បវត្តិ

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងក្បែរវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៥៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh